# អភិវឌ្ឍសមត្ថភាព ប្រតិភូកម្មអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ភ្នំពេញ ១៤ មីនា ២០១៤៖** កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ នៅសាលារាជធានីភ្នំពេញ មានរៀបចំកិច្ចប្រជុំអភិវឌ្ឍសមត្ថភាព ការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ក្រោមអធិបតីភាពលោក ម៉ប់ សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និងលោកសេង រតនៈអភិបាលរងរាជធានីភ្នំពេញ។

លោក ម៉ប់ សារិនមានប្រសាសន៍ថា ការប្រជុំផ្សព្វផ្សាយស្តីពីប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីឱ្យសមាជិកក្រុមប្រឹក្សាស្វែងយល់ឱ្យបានស៊ីជម្រៅដោយនៅពេលខាងមុខនេះ នឹងអនុម័តជូនគណៈអភិបាលរាជធានីភ្នំពេញឱ្យស្របតាមនីតិវិធីការកំណត់របស់ថ្នាក់លើដែលបានប្រតិភូកម្មមក។

បើតាមមន្ត្រីសាលារាជធានីភ្នំពេញបានឱ្យដឹងថា ការប្រតិភូកម្មនេះជាជំហានដំបូងក្នុងការអនុវត្តន៍ផ្ទេរមុខងារ ធនធានទ្រព្យសម្បត្តិមករដ្ឋបាលថ្នាក់ក្រោមជាតិ ខណៈនេះគ្រាន់តែជាជំហានដោយនៅថ្ងៃខាងមុខ បើការអនុវត្តន៍នូវអនុក្រឹត្យខាងលើទទួលបានផលល្អគឺថ្នាក់ជាតិ នឹងប្រគល់មកឱ្យថ្នាក់ក្រោមជាតិទាំងស្រុងតែម្តង៕

*ដកស្រង់ចេញពីកាសែត រស្មីកម្ពុជា លេខ ៦៣៦៩ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤*